**Program:** ឃាតកម្មមុនចូលគេង

**Topic:** Andras PANDY
(ឃាតកដែលសម្លាប់ក្រុមគ្រួសារខ្លួនឯង)
**Categories:** Crime Investigation

**Check: Done**

**Content by:** Prey Reung



---

Hook

សូមស្វាគមន៏មកកាន់ CamId Podcast!

រឿងរ៉ាវដ៏រន្ធត់មួយ ដែលល្បីល្បាញនៅប្រទេសប៊ែលហ៊ិក្ស ដែលសមាជិកម្នាក់ ជាមេគ្រួសារ បានក្លាយខ្លួនទៅជាឃាតកឈាមត្រជាក់ សម្លាប់គ្រួសាររបស់ខ្លួនទាំងមូល មិនញញើតដៃ ដែលសរុបទាំងអស់មាន៦នាក់។

Intro

រឿងដែលនឹកស្មានមិនដល់នោះគឺ ឃាតកម្នាក់នេះ បានធ្វើអោយ កូនស្រីម្នាក់ ក្នុងចំណោមគ្រួសារនោះ បែរជាជួយគេ ក្នុងការសម្លាប់បងប្អូនខ្លួនឯងទៅវិញ ផងដែរ។

ដោយឡែក ឃាតកដែលជាឪពុក ត្រូវបានគេស្គាល់ថា ជាឃាតកដែលសម្លាប់ប្រពន្ធ និងកូនរបស់ខ្លួន ចាប់បំពានសាច់ញាតិខ្លួនឯង និងសម្លាប់ រួចហើយរំលាយសាកសព ជាមួយនឹងទឹកអាស៊ីត យ៉ាងសាហាវព្រៃផ្សៃជាទីបំផុត។

សំណួរសួរថា តើឃាតកដែលជាឪពុកជាអ្នកណា មានប្រវត្តិបែបណា ហើយហេតុអ្វី បានជាកូនស្រីរបស់គេ ក្លាយជាឃាតកដូចគេដែរ?

Body

រឿងរ៉ាវ ផ្តើមចេញពីបុរសម្នាក់ឈ្មោះថា Andras Pandy។ Andras កើតនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩២៧ នៅក្នុងទីក្រុង Czechoslovakia នៃប្រទេសហុងគ្រី។

Andrasគឺ ជាអ្នកសិក្សា ខាងផ្នែកសាសនវិទ្យា តាមបងប្រុសរបស់គេ។ ក៏ប៉ុន្តែបន្ទាប់ពីការបរាជ័យ បដិវត្តន៍នៃប្រទេសហុងគ្រីនៅឆ្នាំ ១៩៥៦ Andras និងប្រពន្ធទី ១ របស់គេ ឈ្មោះIlona Sores បានភៀសខ្លួនទៅប្រទេសប៊ែលហ្សិក ដែលជាកន្លែង ដែលគេបានក្លាយជាបព្វជិត ប្រឆាំងតវ៉ា ចំពោះសហគមន៍ប្រូតេស្តង់ អឺស្លាមហុងគ្រីតូចមួយ ដែលត្រូវបានសមាមិត្តរួមក្រុម ស្វាគមន៍គេយ៉ាងកក់ក្តៅ។

គេទៅនោះ ដោយសារតែមានសាសនវិទូ សញ្ជាតិស្វីសដ៏ល្បីល្បាញម្នាក់ ដែលមានឈ្មោះថា Karl Barth ។

នៅទីនោះ គេមិនទាន់ក្លាយជាបុព្វជិតផ្លូវការនោះទេ តែ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងកំឡុងពេលម៉ោងដែលគេបង្រៀនក្រុមសាសនិកទាំងនោះ គេ តែងតែឆ្លៀត ធ្វើបាបសហគមន៍អ្នកគាំតូចតាច ផ្នែកហិរញ្ញវត្ថុ ដោយយកឈ្នះលើភាពឆោតល្ងង់របស់ពួកគេ ដោយ Andras បានសុំប្រាក់កម្ចី និងការគាំទ្រផ្នែកហិរញ្ញវត្ថុពីសាសនាចក្របែលហ្សិក ហើយគេមិនបានសងវិញនោះទេ ។

បើនិយាយពីគ្រួសាររបស់ Andras វិញ គឺគេមានកូនចំនួន៣នាក់ ជាមួយប្រពន្ធទីមួយរបស់គេ គឺIlona ។ ក្នុងចំណោមនោះ មានកូនស្រីម្នាក់ឈ្មោះ Agnes និងកូនប្រុសពីរនាក់ Daniel និងZoltan ។

មិនយូរប៉ុន្មាន បន្ទាប់ពីកំណើត Zoltan Andras ក៏បានចោទប្រកាន់ប្រពន្ធរបស់គេ ថាIlona មិនស្មោះត្រង់នឹងគេ រួចហើយក៏យកលេសនេះ មកបែកបាក់ពីនាង ។

Ilona បានចាកចេញជាមួយកូនប្រុសពីរនាក់របស់នាង ដោយបន្សល់ទុកកូនស្រីតែម្នាក់ឯងជាមួយAndras ។

នេះគឺដើមចមដំបូង នៃសុបិន្តអាក្រក់នាពេលខាងមុខ ព្រោះ Andrasបានចាប់បំពាន Agnes ម្តងហើយម្តងទៀត តាំងពីអាយុ ១១ ឆ្នាំ មកម្លេះ ។

ក្រោយមក Andras ចាប់ផ្តើមទៅលេងប្រទេសហុងគ្រី ជាប្រចាំ ហើយប្រើសេវាកម្មណាត់ជួបមនុស្សផ្សេងៗគ្នា និងបំពានស្ត្រីស្លូតត្រង់ជាច្រើននាក់ទៀតផង។

ជារឿយៗ គេប្រើឈ្មោះ និងវិជ្ជាជីវៈក្លែងក្លាយ នៅក្នុងការផ្សព្វផ្សាយផ្សេងៗ។ ដែលគ្រានោះហើយ គឺជាពេលដែលAndras បានជួបប្រពន្ធទី ២ របស់គេ ឈ្មោះថា Edit Fintor ដែលបានរៀបការនៅពេលនោះ។

គួរបញ្ជាក់ផងដែរថា Edit Fintor ជាស្ត្រីដែលមានប្ដីរួចហើយ ហើយក៏មិនទាន់បែកបាក់ពីប្ដីចាស់ដែរ។ មានន័យថា Andras គឺជាប្រុសកំណាញ់របស់នាង។

ពេលនោះ ប្ដីដើមរបស់ Edit បានអះអាងថា Andras បានលួងលោម និងបញ្ចុះបញ្ចូលអោយប្រពន្ធរបស់គាត់ ឱ្យព្រមទៅរស់នៅជាមួយគេ នៅប៊ែលហ្សិកដោយយកកូន ៗ របស់ពួកគេ ទៅជាមួយផងដែរ ព្រោះគ្រានោះ Edit មានកូនស្រីបីនាក់ជាមួយប្ដីដើមរបស់នាង គឺTunde, Timea និង Andrea។

មិនយូរប៉ុន្មាន បន្ទាប់ពីនាងរៀបការជាមួយAndras ពួកគេក៏មានកូនពីរនាក់ថែមទៀត។ បន្ទាប់មកAndras បានចាប់បំពាន និងធ្វើឱ្យកូនស្រីពៅរបស់គេ ឈ្មោះ Timea មានផ្ទៃពោះ ។

Timea បានសារភាព ពីការបំពានផ្លូវភេទ ពីសមាជិកគ្រួសារ ប៉ុន្តែត្រូវគ្រួសាររបស់នាង មិនអើពើនឹងនាង

បន្ទាប់ពីហេតុការណ៍នេះបានកើតឡើង នាងត្រូវបានគេបញ្ជូនអោយទៅរស់នៅក្នុងផ្ទះ ជាមួយកូនស្រីច្បងរបស់ Andras គឺAgnesនោះឯង។

នៅពេលនេះ ចរិកព្រៃផ្សៃរបស់Agnes ក៏បានកាត់ទៅតាមឪពុករបស់គេ ហើយក៏បានធ្វើអោយនាងព្យាយាមសំលាប់ Timea ដោយយកបន្ទះដែកមកវាយសម្លាប់នាង នៅក្នុងបន្ទប់ក្រោមដីផ្ទះរបស់ពួកគេ ព្រោះដោយសារតែការច្រណែនTimeaជាមួយAndrasដែលជាឪពុករបស់ខ្លួននោះឯង។

តែសំណាងល្អ Agnes ត្រូវបានគេចូលមកឃាត់
ហើយTimeaត្រូវបានបញ្ជូនទៅមន្ទីរពេទ្យបន្ទាប់ពីហេតុការណ៍នេះកើតឡើង។

Timea បាននិយាយអំពីការចាប់បំពាន និងការប៉ុនប៉ងធ្វើឃាតម្តងទៀត ប៉ុន្តែការអះអាងរបស់នាងនៅតែត្រូវបានច្រានចោល។

ទីបំផុត នាងបានផ្តល់កំណើតកូនប្រុសម្នាក់នៅឆ្នាំ ១៩៨៦ ហើយរួចក៏រត់គេចខ្លួន
ទៅប្រទេសកាណាដាបាត់ទៅ។

នេះអាចនិយាយបានថា វាគឺជាសំណាងរបស់នាង ដែលនាងសម្រេចចិត្តរត់គេចខ្លួនពីឪពុក
និងកូនបិសាចទាំងពីរនេះ។

រឿងរ៉ាវរបស់Timea ក៏បានធ្វើអោយទំនាក់ទំនងរវាងម្តាយនាង និងAndras ឈានទៅរកភាពប្រេះឆាពោលគឺ មុនពេលដែល Timea ចាកចេញ នាងបានប្រាប់ម្តាយរបស់នាង អំពីការបំពានរាងកាយនាងដែលបានប្រព្រឹត្តដោយAndras ហើយថាគេ គឺជាឪពុករបស់កូនប្រុសនាង។
នេះគឺជាមូលហេតុដែលបណ្តាលឱ្យមានការឈ្លោះប្រកែកគ្នាយ៉ាងខ្លាំងរវាង Andras និងEdit។

មិនយូរប៉ុន្មាន នៅឆ្នាំ១៩៨៦  Edit និងកូនស្រីរបស់នាងឈ្មោះ Andrea ក៏បានបាត់ខ្លួនយ៉ាងអាថ៌កំបាំង។ Andrasបានប្រាប់ប៉ូលីសថា នាងបានទុកគេចោល ហើយទៅយកបុរសផ្សេងទៀត រួចក៏ផ្លាស់ទៅនៅប្រទេសអាល្លឺម៉ង់។ គេថែមទាំងបង្ហាញកុស្តតាងមួយចំនួនទៅកាន់ប៉ូលិស ដើម្បីបញ្ជាក់ថានេះជាការពិតទៀតផង។

២ឆ្នាំក្រោយមក ពោលគឺនៅឆ្នាំ១៩៨៨
ប្រពន្ធទីមួយរបស់Andras គឺIlonaនិងកូនប្រុសដើមរបស់គេទាំងពីរ ក៏បានបាត់ខ្លួន ។ Andras បានអះអាងថា ពួកគេបានផ្លាស់ទៅនៅប្រទេសបារាំង បន្ទាប់មក បានអះអាងថា ពួកគេទៅនៅអាមេរិកខាងត្បូង។

ក្រោយមក នៅឆ្នាំ ១៩៩០ បន្ទាប់ពីបញ្ជូន Agnes ទៅដើរលេងជាមួយកូន ៗរបស់គេ ស្រាប់តែកូនស្រីរបស់គេម្នាក់ទៀតគឺ Tunde បានបាត់ខ្លួន។ ហើយគ្រានោះ Andras បានអះអាងថា គេមិនអាចចិញ្ចឹមTundeបានទេ ព្រោះនាងរញ៉េរញ៉ៃ ហើយក៏បណ្តេញនាងចេញពីផ្ទះទៅ។

ដោយមានការពិចារណាលើការសង្ស័យ ដែលកំពុងកើនឡើងចំពោះ Andras ប៉ូលីសហុងគ្រី ក៏បានចូលរួមបើកការស៊ើបអង្កេត។

នៅរដូវក្តៅ Andras តែងតែទៅលេងផ្ទះរបស់គេនៅប្រទេសហុងគ្រី ក្បែរទន្លេDanube ស្រពពេលដែលចំនួនស្ត្រីបាត់ខ្លួននៅទីនោះកំពុងកើនឡើង។

ក្រៅពីនេះ ដោយឡែក ក៏មានមនុស្ស ២នាក់ផ្សេងទៀត ដែលជាបងប្អូនបង្កើតនឹងគ្នាឈ្មោះថា Eva Kincs និង Margit Magyar បានស្គាល់ Andras ហើយក៏ទទួលយកសំណើរបស់ Andras

ដើម្បីទៅរស់នៅជាមួយគេនៅទីក្រុងBrussels ដោយ Andras សង្ឃឹមថា Evaនិង Margitនឹងក្លាយជាប្រពន្ធរបស់គេ។

ក៏ប៉ុន្តែការពិតក៏បានលាតត្រដាង តាមពិតពួកគេទាំងពីរត្រូវបានAndrasចាក់សោនៅក្នុងផ្ទះ ហើយបង្ខំឱ្យបម្រើរូបគេ ដែលធ្វើពួកគេទាំង ២ ត្រូវលួងលោម Andras ដើម្បីបញ្ជូនគេទៅប្រទេសហុងគ្រីវិញ។ ហើយអ្វីដែលមិននឹកស្មានដល់នោះគឺថា Andras ពិតជាបានយល់ព្រមដោយបានបញ្ជូនពួកគេ ទៅប្រទេសហុងគ្រីវិញមែន។

ក្រោយពេលដែល Evaនិង Margit ទៅដល់ប្រទេសហុងគ្រីវិញ ហេតុការណ៍នេះក៏បានបែកធ្លាយទៅដល់ប៉ូលិស។ទីបំផុតនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៧Andrasក៏ត្រូវបានប៉ូលិសចាប់ខ្លួន។

មកដល់ចំណុចនេះ អ្នកទាំងអស់គ្នាប្រាកដជាឆ្ងល់ហើយថា ហេតុអ្វីបានជាកូនៗ និងប្រពន្ធរបស់Andrasទាំងពីរ ចេះតែបាត់ខ្លួនដោយមិនមានមូលហេតុបែបនេះ?

វាំងននៃសេចក្ដីពិតក៏បានរូតឡើង ក្រោយពីកូនស្រីច្បងរបស់Andras គឺAgnes ត្រូវបានចាប់ខ្លួនបន្ទាប់ពី Andras នៅខែវិច្ឆិកា ឆ្នាំ១៩៩៧។

Agnesបានសារភាពថា នាងបានចូលរួមជាមួយAndras ក្នុងអំពើឃាតកម្ម លើសាច់ញាតិរបស់នាងដែលបាត់ខ្លួន។

Agnes ព្រមទទួលខុសត្រូវទាំងស្រុង ទៅលើការសម្លាប់ Ilona ដែលជាម្តាយបង្កើតរបស់នាង ហើយនាងក៏បានសារភាពថា នាងចូលដៃគ្នាជាមួយAndras ក្នុងការសម្លាប់ប្រពន្ធទី ២ របស់ឪពុកនាង និងប្អូនប្រុសពីរនាក់របស់នាង។

នាងបាននិយាយថា នាងមិនជាប់ពាក់ព័ន្ធ នឹងការស្លាប់របស់ប្អូនស្រីចុងរបស់នាងទេ ហើយបានណែនាំថា ឃាតកម្មរបស់ប្អូនស្រចុងរបស់នាង គឺមានតែAndrasតែមួយគត់ ដែលបានប្រព្រឹត្តដោយខ្លួនឯង។

យោងទៅតាមការសារភាពរបស់Agnes យ៉ាងហោចណាស់ ក្នុងករណីឃាតកម្មទាំងនេះ មានជនរងគ្រោះពីរនាក់ ត្រូវបានសម្លាប់ដោយកាំភ្លើងខ្លី។ ហើយសាកសព ត្រូវបានAndrasកាត់ជាផ្នែកៗ ដោយផ្នែកខ្លះ ត្រូវបានរំលាយជាមួយនឹងទឹកអាស៊ីត នៅក្នុងអាងងូតទឹក នៅក្នុងបន្ទប់ក្រោមដី។

ចុងក្រោយ នៅឆ្នាំ២០០២ Andras ត្រូវបានតុលាការទីក្រុងBrussels នៃប្រទេសហុងគ្រី កាត់ទោសអោយជាប់ពន្ធធនាគារ អស់មួយជីវិត ពីបទសម្លាប់សមាជិកគ្រួសារ ៦ នាក់ ហើយប៉ុនប៉ងឃាតកម្ម និងបំពានកូនស្រី ៣ នាក់ ដែលជាលទ្ធផលសាកសពទាំងអស់នោះត្រូវបានរំលាយដោយសារជាតុអាស៊ីតខ្លាំង។

ចំណែកឯ កូនស្រីរបស់គេគឺ Agnes Pandy ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ២១ ឆ្នាំ ពីបទផ្សំគំនិតក្នុងឃាតកម្មចំនួន ៥ ក្នុងចំណោមឃាតកម្មទាំង ៦ នោះ និងការប៉ុនប៉ងឃាតកម្ម។ ក៏ប៉ុន្តែ នាងត្រូវបានដោះលែងអោយមានសេរីភាពនៅក្នុងឆ្នាំ២០១០ ក្រោយពីមេធាវីរបស់នាង ព្យាយាមតវ៉ា ដើម្បីសម្រាលទោសនាង ក្រោមហេតុផលមួយគឺ នាងប្រព្រឹត្តអំពើទាំងនេះ ដោយសារតែនាងមិនអាចគ្រប់គ្រងអារម្មណ៏របស់នាងបាន

ម្យ៉ាងទៀតនាងទទួលរងផលប៉ះពាល់ផ្លូវអារម្មណ៍

តាំងពីឪពុកដ៏ព្រៃផ្សៃរបស់នាងបំពាននាងតាំងពីក្មេងមកម្លេះ។

តែយ៉ាងណាក៏ដោយ ទីបំផុត លុះនៅថ្ងៃទី ២៣ ខែធ្នូឆ្នាំ ២០១៣ András Pándy បានស្លាប់

ដោយសារជរាពាធនៅក្នុងមន្ទីរពេទ្យក្នុងគុក Bruges ។

តាមរយៈរឿងរ៉ាវនេះ យើងអាចស្វែងយល់បានថា ពីគ្រួសារដ៏កក់ក្ដៅមួយ

អាចក្លាយទៅជាគ្រួសារដ៏សោកសៅសង្វេក ប្រសិនបើជាសមាជិកណាមួយក្នុងគ្រួសារ ដើរផ្លូវខុស

ទៅរកផ្លូវងងឹតព្រៃផ្សៃ ដែលខុសយ៉ាងធ្ងន់ធ្ងរ ចំពោះមនុស្សជាតិ។

ទំនួលខុសត្រូវពី អាណាព្យាបាល ទៅលើ កូនៗ ដែលជាសមាជិកគ្រួសារគឺពិតជាសំខាន់ណាស់

ព្រោះការធំធាត់របស់ក្មេងៗ ជាមួយបរិបទគ្រួសារដ៏ល្អ ផ្ដត់គំនិតក៏ល្អ និងការថៃរទាំក៏ល្អ

និងដឹកនាំពួកទៅរកអនាគត់ ដ៏ល្អផងដែរ។

សូមស្ដាប់ ដោយត្រិះរិះពីចារណា។

យើងនឹងជួបគ្នាម្ដងទៀត ក្នុង CamID Podcast ក្រោយ។ សម្រាប់ពេលនេះ សុបិនល្អ និងរាត្រីសួស្ដី។

Links and Resources

https://medium.com/
https://murderpedia.org/
https://www.theguardian.com/